# សិក្សាចក្រ

# Siksācakr

## ទស្សនាវដ្ដីកម្ពុជពិច័យ

*Journal of Cambodia Research*

*Journal de recherche sur le Cambodge*

សូមជូនដល់វិញ្ញាណក្ខន្ធលោកសាស្ត្រាចារ្យ ពីយែរ លុយស៊ីយ៉ាំង ឡាម៉ង់ត៍ និងលោក ស៊ីវ ហ៊ឺ ហ៊ួ

*À la mémoire de Pierre Lucien LAMANT et de SIV Yeu Hour*

*In Memoriam Pierre Lucien LAMANT and SIV Yeu Hour*


## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងកតញ្ញូតាដ៏ជ្រាលជ្រៅចំពោះអ្នកឧបត្ថម្ភ **សិក្សាចក្រ ទស្សនាវដ្ដីកម្ពុជពិច័យ** ពោលគឺ លោកស្រី **សិល្ម៉ា អេរតេហ្គូន** ព្រមទាំងអំណរគុណចំពោះ ៖

លោក **ខេនត៍ ដេវិស**, លោកគ្រូ **ឃីង ហុកឌី**, លោក **ជា សុជាត** (សារមន្ទីរជាតិកម្ពុជា), លោក **ដាញ់ (យ៉ាញ) ហុង**, លោក **ប៊ែរត្រង់ ព័រត៍**, លោកគ្រូ **ម៉ក់ ភឿន**, លោក **ម៉ូរីស អិល្មីហ្គើរ**, អ្នកគ្រូ **ម៉ែន រ័ត្នសម្បត្តិ**, លោក **រ៉ូបឺត ហ្វោល័រ**, អ្នកស្រី **លីឡាន ឌិល្ល-ក្លាំង**, លោកគ្រូ **វង់ សុធារ៉ា**, កញ្ញា **សៀង តេហ្វានី**, លោកបូជាចារ្យ **ហ្វ្រង់ស័រ ប៉ុងស្ហូង់**, លោកស្រី **អ៊ី ដារី** និង **បណ្ណសារដ្ឋានជាតិកម្ពុជា**, លោកស្រី **ឡូអ៊ីស ដឺ ម៉េនីល**, លោកស្រី **អ៊ុក ក្រឹស្នា**, **សាលាបារាំងចុងបូព៌ា**, **ផលិតកម្ម ឌីយ៉ាហ្វាណា** និង **ផលិតកម្ម កាទ្រីន ឌុយសារត៍ ប្រូឌុកស៊ីយ៉ុង (សេ.ដេ.ប៉េ.)** ។

### *Acknowledgements*

The editorial team of *Siksācakr: Journal of Cambodia Research* wishes to express its special gratitude to Ms. Selma ERTEGUN for supporting the journal. We also espress our thanks to:

### *Remerciements*

L'équipe éditoriale de *Siksācakr, Journal de recherche sur le Cambodge* tient à exprimer toute sa reconnaissance à M[me] Selma ERTEGUN qui soutient la revue, ainsi que ses remerciements à :

CATHERINE DUSSART PRODUCTIONS (CDP), CHEA Socheat, DANH Hong, Kent DAVIS, DIAPHANA PRODUCTIONS, Ly Lan DILL-KLEIN, ÉCOLE FRANÇAISE D'EXTRÊME-ORIENT, Maurice ELMIGER, Robert FOWLER, KHING Hoc Dy, MAK Phoeun, MEN Rath Sambath, Lois de MENIL, Père (Father) François PONCHAUD, Bertrand PORTE, SIENG Téphanie, UK Krisna, VONG Sotheara, Y Dary (National Archives of Cambodia).

## អ្នកបកប្រែ និងបណ្ណាធិការ

អ្នកស្រី **ឃួន វិច្ឆិកា** កញ្ញា **ឆោម គន្ធា** អ្នកស្រី **ជា ប៊ុនណារី** លោក **លី សុខជា** លោក **វង់ សុធារ៉ា** លោក **ហុង មករា** លោក **អ៊ឹម លីម** និងលោកបណ្ឌិត **អ៊ុន លាង** បានបកប្រែអត្ថបទទាំងនេះពីភាសាបារាំងនិងអង់គ្លេសមកជាភាសាខ្មែរ ។ លោក **ចាប ប្រេម** កញ្ញា **ឆោម គន្ធា** អ្នកស្រី **ជា ប៊ុនណារី** លោកបណ្ឌិត **មីស្ហែល ឫទ្ធី អង់តែល្ម** លោក **ហុង មករា** លោក **ហៀប ច័ន្ទវិចិត្រ** លោក **អ៊ឹម លីម** និងលោកបណ្ឌិត **អ៊ុន លាង** បានពិនិត្យផ្ទៀងផ្ទាត់និងរៀបរៀងឡើងវិញជាលើកដំបូង ។ លោកបណ្ឌិត **មីស្ហែល ឫទ្ធី អង់តែល្ម** និងកញ្ញា **ឆោម គន្ធា** បានពិនិត្យផ្ទៀងផ្ទាត់វិញ្ញាសាចុងក្រោយ និងសរសេរឡើងវិញ ។

### *Translation and Editing*

The articles were translated from French and English into Khmer by Ms. CHEA Bunnary, Ms. CHHOM Kunthea, Mr. HONG Makara, Mr. IM Lim, Ms. KHUON Vichheka, Mr. LY Sokchea, Mr. VONG Sotheara, and Dr. UN Leang. The proofreading and editing were done by Dr. Michel Rethy ANTELME, Mr. CHAP Prem, Ms. CHEA Bunnary, Ms. CHHOM Kunthea, Mr. HIEP Chan Vicheth, Mr. HONG Makara, Mr. IM Lim, and Dr. UN Leang. Dr. Michel Rethy ANTELME and Ms. CHHOM Kunthea rewrote the final versions.

សិក្សាចក្រ Siksācakr លេខ ១២-១៣ គ.ស. ២០១០-២០១១ N^os 12-13 (2010-2011)

លំនាំដើម ........................................ ៥

*ដោយ ស៊ិន សំណាង*

កថាមុខ ........................................ ៨

*ដោយ ឡូអ៊ិស ដឺ ម៉េនីល* (Lois DE MENIL)

អារម្ភកថា ........................................ ១០

*ដោយ ហ្សង់-ហ្វ្រង់ស្វាស់ ក្លាំង* (Jean-François KLEIN)

ការគ្រប់សង្កត់អាណានិគម និងទំនើបភាវូបនីយកម្មនៅកម្ពុជា ........................................ ២៣

*ដោយ ម៉ាថ្យឺ ហ្គេរ៉ាំង* (Mathieu GUÉRIN)

សាសនទូតកាតូលិក ហ្សង់-ក្លូដ មីស្ឆ (គ.ស. ១៨០៥-១៨៧៣) ៖ សាក្សីដ៏ប្លែក និងតួអង្គមុខពីរ នៃព្រឹត្តិការណ៍អាណានិគមនៅកម្ពុជា ........................................ ៣៥

*ដោយ ប៊ែរណារដ៍ ប៉ាតារី* (Bernard PATARY)

និវេទន៍ស្តីពីនគរខ្មែរ ដោយលោក ប៉េទ្រុស ទ្រឿង វិញគី ........................................ ៦០

*ដោយ ង្វៀន ថេអាញ់* (NGUYỄN Thế Anh)

កុបកម្មនៅកម្ពុជា (គ.ស. ១៨៨៥-១៨៨៦) និងផលវិបាកមកលើរដ្ឋបាលផ្ទៃក្នុងនៃព្រះរាជាណាចក្រ ...... ៧០

*ដោយ អេរិក ហ្គោហ្សូស្សូ* (Éric GOJOSSO)

ការធ្វើឃាតលោករ៉េស៊ីដង់ បារដេស (គ.ស. ១៩២៥) ៖ បុព្វនិមិត្តនៃការបះបោរក្នុងប្រទេសកម្ពុជាសម័យអាណានិគម ........................................ ៨៣

*ដោយ ដេវិឌ ឆាណ្ឌល័រ* (David CHANDLER)

កំណត់ហេតុស្តីពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅកូសាំងស៊ីន ៖ រយៈពេលចាប់តាំងពីគម្រោង (ទសវត្សរ៍ឆ្នាំ ១៩៣០) ដល់ស្ថាដែមិនឋិតថេរ (គ.ស. ១៩៤២-១៩៤៥) ........................................ ១០៩

*ដោយ ប៉ាស្កាល់ ប៊ួរដូ* (Pascal BOURDEAUX)

ឫសគល់នៃសម័យអាណានិគមនៅក្នុងវិស័យសុខាភិបាលនៅប្រទេសកម្ពុជា ........................................ ១២៦

*ដោយ អាន្ន អ៊ីវន្ន ហ្គីយូ* (Anne Yvonne GUILLOU)

យុទ្ធសាស្ត្ររបស់គ្រឹះស្ថាន ដឺនីស៍ប្រ៊ែរស៍ នៅកម្ពុជា (គ.ស. ១៨៦៣-១៩៦២) ៖ ទស្សនៈនិងការកំណត់រចនាសម្ព័ន្ធទីផ្សារខ្មែរ ដោយគ្រឹះស្ថានពាណិជ្ជកម្មបារាំងសែសមួយ ........................................ ១៤៥

*ដោយ ឌែលហ្វ៊ីន ប្វាស្សារី* (Delphine BOISSARIE)

កៅស៊ូនិងពូជសាសន៍នៅជនបទកម្ពុជា នាសម័យអាណានិគម ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩២០ ដល់ឆ្នាំ ១៩៥៤ ........................................

... ១៦០
*ដោយ អ:សុ មិច* (Mitch ASO)

ដីដាំកៅស៊ូនៅប្រទេសកម្ពុជា ៖ ប្រវត្តិនៃ « ដីសុវណ្ណភូមិ » អាណានិគមមួយ
ក្នុងចន្លោះពេលសង្គ្រាមលោកទាំងពីរ .................................................. ១៧៧
*ដោយ ម៉ារីយ៉ាន្ន ប៊ូស្ទឺរ៉េត៍* (Marianne BOUCHERET) →

អណ្តូងត្បូងថ្មនៅខេត្តចន្ទបុរីនិងត្រាច (គ.ស. ១៨៩៣-១៩០៧) ៖ គោលដៅដ៏ធំធេងក្នុងការតស៊ូ
រវាងចក្រភពបារាំងសែសនិងអង់គ្លេស .................................................. ១៩១
*ដោយ ក្សាវីយេ៉រ៍ ហ្ក្រាល្ល* (Xavier GRALL)

លោកឧត្តមសេនីយ៍ ដឺ បេយ៍លីយេ៉ ៖ តួអង្គដ៏ចម្លែកនៃបេតិកភណ្ឌបនីយកម្មឥណ្ឌូចិន ? ............. ២១៤
*ដោយ ហ្សង់-ហ្វ្រង់ស្វាស៍ ក្លាំង* (Jean-François KLEIN)

ពីសាលាសំណាក់មកមហាសណ្ឋាគារ ៖ ឧស្សាហកម្មសណ្ឋាគារនៅអង្គរ នាសម័យអាណានិគម ....... ២៣១
*ដោយ អាលីន ដឺម៉េយ៍* (Aline DEMAY)

« ទោះជាគ្មានអ្វីទៀតទេ ក៏មានអង្គរដែរ » ។ មេរៀនបានមកពីផ្លូវថ្នល់ក្នុង **ទីក្រុងព្រៃនិទ្រា ៖ ពីព្រៃនគរទៅអង្គរតាមរថយន្ត** ដោយលោកម្ចាស់ ដឺ ម៉ុងតិប៉ង់ស្យេរ៍ ....................... ២៥០
*ដោយ ស្តេបហ្វានី ស៊ុផាផន ផុងស:វ៉ាត់ឌី* (ສະແຕບຟານີ ສຸພາພອນ ພົງສະຫວັດດີ Stéphanie PONSAVADY)

ទស្សនៈផ្សេងគ្នាស្តីពីសិល្បៈនៅក្រោមរបបអាណានិគម រវាង ហ្សេក ប្រ៉េគ្គាស៍លីយ៉េរ៍ (គ.ស. ១៨៨៧-១៩៤៥)
និង វិកទរ តារឌីយើ (គ.ស. ១៨៧០-១៩៣៧) ........................................ ២៦៩
*ដោយ ការ៉ូលីន ហែរបឺឡាំង* (Caroline HERBELIN)

ទិន្នន័យដើម្បីយល់ពីប្រវត្តិសារមន្ទីរ អាល់ប៊ែរត៍ សារ៉ូត៍ ក្រុងភ្នំពេញ ......................... ២៨៩
*ដោយ ហ្គាប្រ៊ីយែល្ល អាប្ប* (Gabrielle ABBE)

« ក្រោមម្លប់ប្រាសាទសម័យអង្គរ » ៖ សម័យអាណាព្យាបាលពោរពេញដោយក្តីស្រងេះស្រងោច
ក្នុងរឿងប្រលោមលោករបស់ ហ្សេក ប្រ៉េគ្គាស៍លីយ៉េរ៍ .................................. ៣១២
*ដោយ ស៊ូសាន់ គ. ឌិក្សុន* (Susan C. DIXON)

មនុស្សព្រៃ និង មនុស្សស៊ីវិល្បែនៅក្នុងដំណែលអង្គរ ៖ តើមានអត្តសញ្ញាណអក្សរសិល្ប៍បែបណាខ្លះ
សម្រាប់ប្រទេសកម្ពុជានៅក្នុងស្ថានភាពអាណានិគម ? .................................. ៣៣០
*ដោយ ហង់រី គូប៉ុង* (Henri COPIN)

កម្ពុជាសម័យអាណានិគមតាមរយៈខ្សែភាពយន្ត ៖ រឿង **ទំនប់ទប់មហាសមុទ្រប៉ាស៊ីហ្វិក**
ដោយលោក ប៉ាន់ រិទ្ធី ......................................................... ៣៥៥
*ដោយ ម៉ៃខឹល ជី. វ៉ុន្ន* (Michael G. VANN)

~๑๑~

កំណែពាក្យខុសក្នុង **សិក្សាចក្រ** លេខ ១២-១៣ (ច្បាប់ជាភាសាបារាំងនិងអង់គ្លេស) ............. ៣៦២

# លំនាំដើម

*ដោយបណ្ឌិត ស៊ិន សំណាង, សាស្ត្រាចារ្យប្រវត្តិសាស្ត្រកម្ពុជាសហសម័យ និងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា*

វប្បធម៌និងប្រពៃណីខ្មែរ មានអាយុកាលពីរពាន់ឆ្នាំហើយ ។ ចន្លោះសតវត្សរ៍ទី ១០ និងទី ១៤ គឺជារយៈពេលដ៏រុងរឿងបំផុតនៃអរិយធម៌នេះ ។ អាណាចក្រធំទូលាយ រីឯអំណាចក៏ខ្លាំងក្លាទាំងនេះ មានប្រាង្គប្រាសាទសម័យអង្គរជាសាក្សីមិនងាយសាបសូន្យ ។ ចំណែកឯសម័យក្រោយអង្គរ (ចាប់ផ្តើមពីសតវត្សរ៍ទី ១៥ មក) មានវិបត្តិនយោបាយ និងសង្គ្រាមស្នូនជាប់ ៗ គ្នា ធ្វើឲ្យស្រុកមួយនេះចុះទន់ខ្សោយ ។

នៅឆ្នាំ ១៨៦៣ ក្នុងរាជ្យព្រះចៅ ណាប៉ូឡេអុង ទី ៣ បារាំងសែសបានសង្គ្រោះនគរខ្មែរ ដោយសារនយោបាយពង្រីកអាណានិគមរបស់ខ្លួន ហើយគ្រប់គ្រងស្រុកខ្មែរអស់ ៩០ ឆ្នាំ ។ បើនិយាយតាមផ្លូវនយោបាយ កិច្ចព្រមព្រៀងឆ្នាំ ១៨៨៤ រវាងលោក ស្ហាលិស៍ ថុំសុន និង ព្រះបាទ នរោត្តម គឺជាទីចាប់ផ្តើមពិតប្រាកដនៃសម័យអាណា-និគម ។ ប៉ុន្តែ ទាល់តែដល់ឆ្នាំ ១៨៩៧ ទើបបារាំងសែសបានអំណាចពេញដៃ អាចគ្រប់គ្រងលើបូរណភាពខ្មែរ ។ ចាប់ពីឆ្នាំ ១៩២០ មក បារាំងសែសបានលាក់ខ្លួនក្រោមព្រះរាជប្រកាសដើម្បីរឹតពន្ធអាករ ធ្វើឲ្យរាស្ត្រជួបមហន្តរាយក្នុងអំឡុងឆ្នាំ ១៩៣១-១៩៣៧ នៅពេលមហាវិសម្ពាធទសវត្សរ៍ឆ្នាំ ១៩៣០ ។ ប៉ុន្តែ ជាធម្មតា « ពាក្យថា ធ្វើអាណានិគម-កិច្ច មានន័យថា ឲ្យផង យកផង » ។ ទន្ទឹមនឹងអំពើគាបសង្កត់លើរាស្ត្រខ្មែរ អាណានិគមបារាំងសែសក៏ពាំនាំមកឲ្យរាស្ត្រនេះវិញ នូវគុណប្រយោជន៍នៃអរិយធម៌របស់ខ្លួន ។ មុននឹងសម័យអាណានិគមកិច្ច តេជគុណ ហ្សង់-ក្លូដ មីស្ចជាបេសកទូតសង្ឃកាតូលិក ចេះនិយាយខ្មែរ ហើយមានទំនាក់ទំនងយ៉ាងល្អជាមួយព្រះបាទ អង្គដួង បានដើរតួជាខ្សែចំណងរវាងរាជធានីឧដុង្គនិងប៉ារីស ។ បព្វជិតរូបនេះ ក៏បានសម្រេចចងសម្ព័ន្ធមេត្រីរវាងខ្មែរនិងបារាំងសែស ។

នៅពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី ១៩ អ្នករដ្ឋបាលបារាំងសែសខ្លះបានចំណាយកម្លាំងក្រៅពីកិច្ចរដ្ឋបាលរបស់ខ្លួន ខំប្រឹងស្វែងយល់ពីអតីតកាលនៃស្រុកខ្មែរ ដើម្បីនឹង « យកឈ្នះចិត្តនិងវិញ្ញាណ » ឲ្យបាន ។ លោក អាដេម៉ារ ឡឺក្លែរ [១] ជាអ្នករដ្ឋបាលបារាំងសែសដ៏ល្អ ប៉ុន្តែ គេស្គាល់លោកច្រើនជាងតាមរយៈស្នាដៃនាំឲ្យស្គាល់សង្គមខ្មែរ ដែលលោកបានរស់នៅជាមួយ អស់ពេលជិតម្ភៃឆ្នាំ ពីឆ្នាំ ១៨៨៦ ដល់ ១៩១០ ។ នៅក្នុងស្នាដៃ **ឡេ្វ ឝូដតំម្បូដហ្សីយ៉ាំខ** (ច្បាប់ក្រមខ្មែរ) បោះពុម្ពឆ្នាំ ១៨៩៨ លោកសរសេរដាក់ក្នុងលំនាំដើមថា លោកមិនបានធ្វើការតែឯងទេ ។ លោកបានការជួយជ្រោមជ្រែងពេញទំហឹង ពីសំណាក់ថ្នាក់ដឹកនាំ រួមមាន លោក ប៉ូល ឌូមែរ អគ្គទេសាភិបាលឥណ្ឌូចិនបារាំងសែស ដែលព្រមឧបត្ថម្ភស្នាដៃនោះ មកបោះពុម្ព ព្រមទាំងលោក អាឡិចសង់ដ្រឺ ឌុយកូស៍ ជារ៉េស៊ីដង់ស៊ុប៉េរីយ៉ឺរនៃសាធារណរដ្ឋបារាំងសែសប្រចាំនៅកម្ពុជា (គ.ស. ១៨៩៧-១៩០០) ដែលចាប់អារម្មណ៍នឹងស្នាដៃនោះដែរ ។ លើសពីនេះទៀត នៅមានសហសេវិករបស់លោក ឡឺក្លែរ ដែល « មានកិច្ចត្រូវជួយលើកស្ទួយជាតិសាសន៍នេះ ជួយជំរុញ និង ដឹកនាំពួកគេនៅលើគន្លងអរិយធម៌ » ។ លោក អាដេម៉ារ ឡឺក្លែរ បានខិតខំ « ធ្វើឲ្យគេស្គាល់កាន់តែច្បាស់ ពីជាតិសាសន៍មួយ ដែលធ្លាប់តែថ្កុំថ្កើង ហើយជាទីកោតសរសើរចំពោះស្នាដៃពួកគេពីមុន ។ បើយល់ពីជាតិសាសន៍នេះច្បាស់ហើយ យើងនឹងអាចជួយបាននៅពេលអនាគត លុះត្រាតែពួកយើងចេះគ្រប់គ្រង និងដឹកនាំពួកគេបានត្រឹមត្រូវ » ។

---

**(១)** ឈ្មោះរបស់លោក ឡឺក្លែរ ជួនសរសេរ អាដេម៉ារ ជួនសរសេរ អាដេម៉ារដ៍ ៕

នៅអំឡុងពាក់កណ្ដាលទី ១ នៃសតវត្សរ៍ទី ២០ វិញ បារាំងសែសជាម្ចាស់អាណានិគម ខំរៀបចំស្ថាប័ននយោបាយ ដើម្បីអភិវឌ្ឍស្រុកខ្មែរលើវិស័យនានា ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បានសម្ភោធនៅខែឧសភា ឆ្នាំ ១៩៣០ ក្រោមអធិបតីភាពព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស លោកហ្វ្រេរណង់ ឡាវីត៍ ជារ៉េស៊ីដង់ស៊ុប៉េរីយ៉ឺរ (គ.ស. ១៩២៩-១៩៣២) និង លោក ពីយែរ ប៉ាស្គីយេ៉រ៍ ជាអគ្គទេសាភិបាល ។ អគ្គទេសាភិបាលរូបនេះ បានជូនពរ «ដល់ពុទ្ធសាសនបណ្ឌិត្យ ដែលជាផ្កានៃឧត្ដមគតិអាស៊ី ដែលរីកក្រោមក្រសែភ្នែកបារាំងសែស ពីសំណាក់ស្ថាបនជនមួយនាក់ដែលចេះដឹងគុណ» ។ លើសពីនេះ ក្នុងឱកាសសម្ភោធសាលាបុស្សីកែវនៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៣៩ លោករ៉េស៊ីដង់ស៊ុប៉េរីយ៉ឺរ ឡេអុង ធីបូដូ (គ.ស. ១៩៣៦-១៩៤១) ក៏បានសរសើរក្នុងសុន្ទរកថាលោកថា៖ «ជាតិសាសន៍ដែលបានលើកថ្មកជាប្រាសាទអង្គរ ដោយកម្លាំងញើសឈាម ហើយដែលឥឡូវនេះនៅតែខំធ្វើស្រែនិងដាំពោតពេញព្រះរាជអាណាចក្រ បញ្ជាក់ប្រាប់ថា ពួកគេមានការតស៊ូកម្លាំងបាយដូចជាតិសាសន៍ដទៃដែរ» ។ ក្រៅពីការជ្រោមជ្រែងពីសំណាក់អ្នករដ្ឋការ ពួកអ្នកស្រាវជ្រាវបារាំងសែស ក៏មានមុខមាត់សម្បើមដែរខាងផ្នែកខេមរវិទ្យា ។ ការបង្កើតបេសកកម្មបុរាណវិទ្យានៃឥណ្ឌូចិននៅឆ្នាំ ១៨៩៨ ដែលក្រោយមក ក្លាយទៅជាសាលាបារាំងចុងបូព៌ានៅឆ្នាំ ១៩០១ បានផ្ដល់ជាសន្ទុះយ៉ាងខ្លាំងដល់ខេមរវិទ្យា ។ ពួកអ្នកស្រាវជ្រាវ ពិតជាបានគាស់កកាយប្រទេសកម្ពុជា ។ ពួកគេបានចុះមើលនិងព័ណ៌នាប្រាសាទ បានអាន និងបកស្រាយសិលាចារឹក ព្រមទាំងបានធ្វើកំណាយជាច្រើនផងដែរ ។ ការងារអស់នេះ បានបោះពុម្ពចេញផ្សាយក្នុងន័យឲ្យគេឯងស្គាល់វិស័យផ្សេង ៗ នៃស្រុកខ្មែរ ជាពិសេសទៀតនោះ គឺថា ដើម្បីចងក្រងដំណាក់កាលសំខាន់ ៗ នៃប្រវត្តិសាស្ត្ររបស់ស្រុកនេះ ។

ទាក់ទងនឹងប្រវត្តិស្រុកខ្មែរនាសម័យអាណានិគម ឥឡូវនេះ យើងអាចរកបាននូវការងារស្រាវជ្រាវ និងនិក្ខេបបទថ្នាក់បណ្ឌិតជាច្រើនស្ដីពីអំឡុងពេលពាក់កណ្ដាលចុងក្រោយនៃសតវត្សរ៍ទី ១៩ ។ ក្រៅពីនេះ ក៏មានការបោះពុម្ព



អ្នករាជការសម័យអាណាព្យាបាលបារាំងសែស ។

ទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នៅដើមសតវត្សរ៍ទី ២០ ដែរ ។ ដោយឡែក ស្នាដៃធំ ៗ ទាក់ទងនឹងសម័យប្រហែលពីប្រមាណឆ្នាំ ១៨៦៣ ដល់ ១៩២០ រួមមាននិក្ខេបបទតតិយភូមិរបស់លោក អាឡាំង ហ្វូរែស្ត ក្រោមចំណងជើងថា៖ **ប្រទេសកម្ពុជានិងអាណានិគមកិច្ចបារាំងសែស ៗ ប្រវត្តិអាណានិគមកិច្ចមួយដែលគ្មានប៉ះទង្គិច (គ.ស. ១៨៩៧-១៩២០)** និង និក្ខេបបទថ្នាក់បណ្ឌិតរបស់លោក ពីយែរ លុយស៊ីយ៉ាំង ឡាម៉ង់ត៍ ក្រោមចំណងជើងថា៖ **ករណីព្រះអង្គម្ចាស់ យុគន្ធរ ៗ ការវិះពិនិត្យរឿងរ៉ាវក្នុងសម័យអាណានិគមមួយ** ។ សន្និសីទអន្តរជាតិទីមួយ ស្តីពីខេមរវិទ្យា ក្រោមប្រធានបទ៖ **ចំណេះដឹងពីអតីតកាល និង ការរួមចំណែកទៅនឹងការស្តារ និង ស្ថាបនាប្រទេសកម្ពុជាឡើងវិញ** បានប្រារព្ធធ្វើនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពីថ្ងៃទី ២៦ ដល់ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៩៦ ក្រោមការឧបត្ថម្ភយ៉ាងសកម្មពីសាកលវិទ្យាល័យសូហ្វីយ៉ា ក្រុងតូក្យូ ។ មានអ្នកជំនាញប្រហែល ១០២ នាក់ ពី ១៨ ប្រទេសចូលរួម ។ ជំនួបអន្តរជាតិដ៏ធំនេះ បានលើកស្ទួយកិត្តិយសស្រុកខ្មែរតាមរយៈបទបង្ហាញរបស់វាគ្មិនដ៏សម្បូរបែបនិងដ៏មានតម្លៃ ។ វត្តមានរបស់អ្នកស្រាវជ្រាវទាំងនេះ ក៏បានបង្ហាញផងដែរ នូវចំណាប់អារម្មណ៍ពេញបន្ទុករបស់មិត្តបរទេសយើង ក្នុងការស្ថាបនាប្រទេសកម្ពុជាឡើងវិញ ។ ក្នុងនាមជាអ្នករៀបចំដ៏សំខាន់ម្នាក់ ខ្ញុំបានបោះពុម្ពអត្ថបទទាំងនោះជាពីរភាគ និងជាបីភាសា (ខ្មែរ បារាំង អង់គ្លេស) នៅឆ្នាំ ១៩៩៨-១៩៩៩ ។ លទ្ធផលនៃការស្រាវជ្រាវទាំងនេះ បានចូលរួមចំណែកយ៉ាងធំធេងដល់ការបង្កើនកេរដំណែលប្រវត្តិវិទ្យាខ្មែរ ។

ខ្ញុំបាទសូមក្រើនរំឭកផងដែរ ពីតួនាទីរបស់សមាគមទំនាក់ទំនង និងបណ្តុះបណ្តាលដើម្បីខេមរវិទ្យា (ហៅកាត់តាមភាសាបារាំងថា **អាអេហ្វិក**) ដែលបានបង្កើតនៅឆ្នាំ ១៩៩៧ នៅក្រុងប៉ារីស ដើម្បីរៀបចំជំនួបរវាងអ្នកស្រាវជ្រាវជំនាន់ថ្មី និង អ្នកស្រាវជ្រាវជំនាន់ចាស់ ។ សមាគមនេះគឺជាក្បាលបណ្តាញទំនាក់ទំនងដ៏សំខាន់មួយនៃខេមរវិទ្យានៅស្រុកបារាំង ។ តាមរយៈអាសយដ្ឋានអ៊ិនធើណេតរបស់ខ្លួន សមាគមអាអេហ្វិក សង្ឃឹមថា នឹងអាចពង្រីកទំនាក់ទំនងជាមួយអ្នកស្រាវជ្រាវដទៃទៀត ទាំងបារាំងសែស ទាំងអឺរ៉ុប ទាំងអន្តរជាតិ ហើយសង្ឃឹមថា នឹងអាចចូលរួមផ្សាយចំណេះខាងស្រុកខ្មែរផងដែរ ។ ក្រៅពីនេះ នៅមានការបោះពុម្ពលេខពិសេស ១២-១៣ នៃ **សិក្សាចក្រ ទស្សនាវដ្តីកម្ពុជពិច័យ** ឆ្នាំ ២០១០-២០១២ ក្រោមចំណងជើងថា៖ « នគរខ្មែរ ៖ ជួបប្រទះគ្នាជាសម័យអាណានិគម » ដោយមានការរៀបរៀងយ៉ាងយកចិត្តទុកដាក់ដោយលោក ហ្សង់-ហ្វ្រង់ស្វាស៍ ក្លាំង ជានិពន្ធនាយកផង ហើយលោកក៏បានសរសេរអារម្ភកថាមួយផង ។ សៀវភៅនេះ គឺជាការចូលរួមចំណែកដ៏មានតម្លៃក្នុងការផ្សាយខេមរវិទ្យា ទាំងនៅស្រុកខ្មែរ ទាំងនៅសាកលលោក ។

សូមគូសសម្គាល់ផងដែរថា ឆ្នាំបោះពុម្ពស្នាដៃនេះ គឺគាប់ជួនជិតត្រូវនឹងខួប ១៥០ ឆ្នាំ ដែលបារាំងសែសធ្វើអាណានិគមកិច្ចប្រទេសកម្ពុជា ។ ជំនួបរវាងបារាំងសែសនិងខ្មែរសម័យអាណានិគម បានបន្សល់ទុកនូវអនុស្សាវរីយ៍ផ្អែមល្ហែមផង ជូរចត់ផង ។ ប្រទេសកម្ពុជា គឺជាដែនអាណានិគមសម្រាប់ចម្រាញ់យកផល មិនមែនជាប្រទេសអាណានិគមយកដីសម្រាប់នៅទេ ម្ល៉ោះហើយម្ចាស់អាណានិគម ផ្តោតសំខាន់លើការទាញយកផលចំណេញ ។ ទោះជាយ៉ាងណាក្តី អាណានិគមបារាំងសែសក៏បន្សល់នូវអនុស្សាវរីយ៍ល្អមិនអាចបំភ្លេចបានមួយ គឺការសង្គ្រោះជាតិខ្មែរ ។

ខ្ញុំសូមសម្តែងការកោតសរសើរដ៏ស្មោះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មិត្តទាំងឡាយ រួមមានលោកស្រីប្រធានមជ្ឈមណ្ឌលខេមរសិក្សា លោកនិពន្ធនាយកប្រចាំលេខពិសេសនេះ ព្រមទាំងអ្នកនិពន្ធអត្ថបទទាំងអស់ ដែលបានរួមចំណែកធ្វើកិច្ចការដ៏មានសារៈសំខាន់លើសលប់មួយនេះ ៕

# កថាមុខ

*ដោយបណ្ឌិត ឡូអិស ដឺ ម៉េនីល, ប្រធានមជ្ឈមណ្ឌលខេមរសិក្សា*

ពេលវេលានៃការបោះពុម្ពទ្វិលេខក្នុងឆ្នាំ ២០១០-២០១១ នៃទស្សនាវដ្ដីកម្ពុជពិច័យនៅឆ្នាំ ២០១៣ អំពីប្រធានបទជាច្រើន ស្ដីពីអាណានិគមនិយម គឺជាឆ្នាំពិសេសដែលរំលឹកពីប្រវត្តិប្រទេសកម្ពុជាក្នុងពេលផ្សេងគ្នា ។ ទី ១ គឺសម្ដេចព្រះ នរោត្ដម ដែលបានសំណូមពរឲ្យបារាំងសែសដាក់អាណាព្យាបាលមកលើកម្ពុជា ជាពេលដែលកម្ពុជាក្លាយជាផ្នែកមួយនៃចក្រភពអាណានិគមបារាំងសែស ។ ទី ២ ឆ្នាំ ២០១៣ ក៏ជាឆ្នាំដែលប្រទេសកម្ពុជារំលឹកខួបឯករាជ្យលើកទី ៦០ មួយឆ្នាំមុនកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ គួរឲ្យសង្វេគផងដែរ នៅដើមឆ្នាំ ២០១៣ ប្រទេសកម្ពុជាក៏ប្រារព្ធបុណ្យកាន់ទុក្ខសម្ដេចព្រះមហាវីរក្សត្រ នរោត្ដម សីហនុ អ្នកដែលដឹកនាំទាមទារឯករាជ្យពីបារាំងសែស ។

ក្នុងកំលុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អ្នកសិក្សាមកពីគ្រប់ផ្នែកនិងតំបន់ បានផ្ដោតការយកចិត្តទុកដាក់ទៅលើអំឡុងពេលអាណានិគម ប្រភពរបស់វា ឥទ្ធិពលមកលើវិស័យនយោបាយនិងសង្គម ហើយនិងកេរដំណែលដែលនៅសេសសល់រហូតមកទល់ពេលនេះ ។ មជ្ឈមណ្ឌលខេមរសិក្សាសូមស្វាគមន៍បណ្ឌិត ហ្សង់-ហ្វ្រង់ស្វាស៍ ក្លាំង ដែលយើងខ្ញុំបានអញ្ជើញឲ្យធ្វើជានិពន្ធនាយកសម្រាប់ការបោះពុម្ពទ្វិលេខនេះ ហើយលោកក៏នឹងទៅធ្វើជាសាស្ត្រាចារ្យទស្សនកិច្ចនៅសាកលវិទ្យាល័យញូវយ៉កក្នុងពេលឆាប់ ៗ នេះដែរ ។

ចាប់តាំងពីការបង្កើតឡើង ១៣ ឆ្នាំមុន បេសកកម្មដោយឡែកមួយរបស់មជ្ឈមណ្ឌលខេមរសិក្សា គឺការផ្លាស់ប្ដូរអក្សរសិល្ប៍វិទ្យាសាស្ត្រក្នុងចំណោមអ្នកស្រាវជ្រាវមកពីប្រទេសផ្សេង ៗ និងជាអន្តរកម្មរវាងអក្សរសិល្ប៍វិទ្យាសាស្ត្រ និងការស្រាវជ្រាវ ។ នេះឆ្លុះបញ្ចាំងតាមរយៈសកម្មភាពបញ្ចូលគ្នារវាងសន្និសីទអន្តរជាតិដែលរៀបចំដោយមជ្ឈមណ្ឌលខេមរសិក្សា និងការបោះពុម្ពទស្សនាវដ្ដីសិក្សាចក្រ ដែលជាទស្សនាវដ្ដីបីភាសា៖ អង់គ្លេស បារាំង និងខ្មែរ ឋិតក្រោមការដឹកនាំដ៏យកចិត្តទុកដាក់ពីសំណាក់សាស្ត្រាចារ្យ មីស្ហែល ឋ្ទី អង់តែល្ម ។ ទស្សនាវដ្ដីសិក្សាចក្របានបោះពុម្ពស្នាដៃអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យនានាជុំវិញពិភពលោកអំពីបញ្ហានេះ ។ មជ្ឈ-មណ្ឌលខេមរសិក្សាក៏បានដឹកនាំសម្របសម្រួលគម្រោងស្រាវជ្រាវរួមគ្នាជាច្រើនផងដែរ ។

បញ្ហាអាណានិគមនិយមនេះ (អត្ថបទទាំងនេះជាការបកប្រែពីការបោះពុម្ពដោយឡែកជាភាសាអង់គ្លេស និងបារាំង) នឹងផ្ដល់កាលានុវត្តនភាព ក៏ដូចជាឯកសារយោងសម្រាប់អ្នកស្រាវជ្រាវខ្មែរវ័យក្មេង ក្នុងការពិចារណាប្រវត្តិសាស្ត្ររបស់ខ្លួន ដែលជាទស្សនៈរបស់អ្នកស្រាវជ្រាវបរទេសអំពីឥទ្ធិពលនៃអាណានិគមនិយមមកលើបរិបទនយោបាយ និងសង្គមនាពេលបច្ចុប្បន្ន ។

មជ្ឈមណ្ឌលខេមរសិក្សា គឺជាមជ្ឈមណ្ឌលស្រាវជ្រាវអាមេរិកាំងនៅក្រៅប្រទេស ទទួលស្វាគមន៍មនុស្សគ្រប់ប្រភេទ និងផ្ដោតលើការស្រាវជ្រាវនិងអប់រំនៅប្រទេសកម្ពុជានិងក្នុងតំបន់ ។ មជ្ឈមណ្ឌលខេមរសិក្សាមានសៀវភៅក្នុងបណ្ណាល័យសម្រាប់ការស្រាវជ្រាវជាង ១៥០០០ ក្បាលនៅខេត្តសៀមរាប ។ មជ្ឈមណ្ឌលខេមរ-សិក្សាក៏គាំទ្រអ្នកស្រាវជ្រាវរយៈខ្លី រៀបចំសិក្ខាសាលា និងបទបង្ហាញ ហើយនិងសន្និសីទអន្តរជាតិផងដែរ ។ មជ្ឈមណ្ឌលខេមរសិក្សាក៏បានបកប្រែអត្ថបទសំខាន់ ៗ ជាភាសាខ្មែរ និងរួមចំណែកពង្រឹងសង្គមស៊ីវិលនៅកម្ពុជាតាមរយៈកម្មវិធីសិក្ខាសាលា និងបទបង្ហាញ ។ យើងខ្ញុំសូមថ្លែងអំណរគុណជាខ្លាំងដល់អ្នកស្រាវជ្រាវជាច្រើន ដែលបានរួមចំណែកដល់ការបោះពុម្ពដ៏មានសារៈសំខាន់ អំពីអាណានិគមនិយមនៅកម្ពុជា ៕




សប្តាហ៍អាណានិគមបារាំងសែស ។

# អរម្ភកថា*

*ដោយបណ្ឌិត ហ្សង់-ហ្វ្រង់ស្វាស៍ ក្លាំង, គ្រូសន្និសីទផ្នែកប្រវត្តិសាស្ត្រាសហសម័យនៃអាស៊ីអាគ្នេយ៍ វិទ្យាស្ថានជាតិនៃភាសានិងអារ្យធម៌ចុងបូព៌ាប្រទេស មជ្ឈមណ្ឌលរ៉ូឡង់ មូស៍នីញេ៉រ៍ (ប៉ារីស-ស៊ីរបោន្ន)*

ចាប់តាំងពីប៉ុន្មានឆ្នាំមុននេះ កម្រងអត្ថបទស្រាវជ្រាវជាភាសាបារាំងស្ដីពីប្រវត្តិកថា (ការសរសេរអំពីប្រវត្តិសាស្ត្រ) បានទទួលឥទ្ធិពលនៃការផ្សាយវិធីសាស្ត្រថ្មី ៗ ពីស្រុកអង់គ្លេសនិងអាមេរិក ជាហេតុនាំឲ្យបង្កើតបាននូវគំរូនិទ្ទស្សន៍ និងឧបករណ៍ស្រាវជ្រាវថ្មី ៗ ។ បម្លាស់ប្ដូរការសិក្សាពីវិទ្យាសាស្ត្រដ៏ចម្បងមួយនេះ ហាក់ដូចជាលេចរូបរាងច្បាស់នៃបដិវត្តន៍ញាណវិទ្យាមួយហើយ ទោះជាគេមិនទាន់រកឈ្មោះដាក់ឲ្យវាបានក៏ដោយ ។ « ប្រវត្តិសាស្ត្រពិភពលោក (Global History) » « ប្រវត្តិសាស្ត្រប្រទាក់គ្នា (Connected History) » « ប្រវត្តិសាស្ត្រចក្រពត្តិថ្មី (New Imperial History) » « ការសិក្សាថ្មីស្ដីពីអាណានិគម (New Colonial Studies) » សុទ្ធតែជាបញ្ញត្តិ ដែលពួកប្រវត្តិវិទូបារាំងច្រើនទៅ ៗ នាំគ្នាទទួលយក ។ ឧបករណ៍ទាំងនេះ អង្រួនទស្សនវិស័យពិភពដែលផ្ដោតលើអឺរ៉ុប ។ វាបង្កឲ្យមានបម្រែបម្រួលរូបដ៏រលូននៃពិភពមួយ ដែលអ្នកសិក្សាពីសម័យក្រោយអាណានិគម ជាពិសេស គឺពួកអ្នកស្រាវជ្រាវ « ឋានៈទាបនិយម » ពីឧបទ្វីបឥណ្ឌា ទាមទាររកអស់ពេលជិត ៣០ ឆ្នាំមកហើយ[១] ។

នៅប្រទេសបារាំង ពួកប្រវត្តិវិទូដែលសិក្សាលើបញ្ហាអាណានិគម បានរងឥទ្ធិពលនៃព្រឹត្តិការណ៍អង់គ្លូសាក់សុងមួយនេះ ដោយយកទៅច្របល់ជាមួយអ្វីដែលពួកគេខ្លួនឯងបានបង្កើតនៅចុងឆ្នាំ ១៩៨០ ជាពិសេស គឺ មីក្រូស្តូរីយ៉ា (រឿងតូច ៗ) ដែលកើតក្រោយពីការស្រាវជ្រាវរបស់ពួកអ៊ីតាលី ឈ្មោះ ជីយ៉ូវ៉ាន់នី ឡេវី (Giovanni Levi) ការឡូ ហ្គីនស្ប៊ីក (Carlo Ginzburg) ព្រមទាំង ការឡូ ប៉ូនី (Carlo Poni) ផង ។ មុនដំបូង ប្រវត្តិវិទូទាំងនេះ បានទទួលទស្សនវិស័យប្រកបដោយចរន្តផ្សេង ៗ គ្នា ដែលបានយកគំនិត តិចក្ដី ច្រើនក្ដី ពីរូបធាតុនិយមប្រវត្តិសាស្ត្រនៃលទ្ធិម៉ាក្សនិយម ដែលផ្ដោតទៅលើរចនាសម្ព័ន្ធផង ឧបរិរចនាសម្ព័ន្ធ (រចនាសម្ព័ន្ធត្រួតពីលើ) ផង និងទៅលើប្រជាករ ហើយក៏បានយកទស្សនវិស័យម៉ាក្រូប្រវត្តិវិទ្យាស្ដីពីពិភពលោក តែក្រោយមក បែរជាពួកគេយកបុគ្គលទៅដាក់ឲ្យចំស្នូលប្រវត្តិសាស្ត្រវិញ ដោយបញ្ចូលមកវិញនូវជីវប្រវត្តិរបស់បុគ្គលទាំងឡាយ ព្រមទាំងវិធីសាស្ត្រព័ណ៌នាតួអង្គ

---

* សូមអានអត្ថបទដើមជាភាសាបារាំង (ទំព័រ ១៣-២០) និងការបកប្រែជាភាសាអង់គ្លេស (ទ. ២១-២៨) ក្នុង **សិក្សាចក្រ ទស្សនាវដ្ដីតម្កល់ពិច័យ** លេខ ១២-១៣ ច្បាប់ជាភាសាបារាំងនិងអង់គ្លេស ។

**(១)** សូមអានជាអាទិ៍ ៖ ទីបេស ចក្រពត្តិ (Dipesh Chakrabarty) **តែប្រែអឺរ៉ុបឱ្យទៅជាខេត្ត ៖ គំនិតសម័យក្រោយអាណានិគមនិងភាពខុសគ្នានៃប្រវត្តិសាស្ត្រ** (*Provincializing Europe: Postcolonial Thought and Historical Difference*) ការបោះពុម្ពផ្សាយរបស់ ស.វ. (សាកលវិទ្យាល័យ) ព្រីនស្តុន គ.ស. ២០០១ ; និង គាយត្រី ចក្រវរ្តិ ស្ពិវ៉ាក (Gayatri Chakravorty Spivak) **តើអ្នកឋានៈទាបអាចនិយាយបានដែរឬ ? ៗ ការរិះគិតពីប្រវត្តិនៃគំនិតមួយ** (*Can the Subaltern Speak? Reflexions on the History of an Idea*) ញូវយ៉ក ការបោះពុម្ពផ្សាយរបស់ ស.វ. កូឡុំបៀ គ.ស. ២០១០ (អាចរកបានតាមអាសយដ្ឋានអ៊ិនធើណេត ៖ http://www.mcgill.ca/files/crclaw-discourse/ Can_the_subaltern_speak.pdf ។ សូមរកអានផងដែរ ៖ សញ្ជ័យ សុព្រហ្មន្យ៉ា (Sanjay Subrahmanyam) ជាភាសាបារាំង **វ៉ាស្កូ ដឺ ហ្គាម៉ា ៗ រឿងនិទាននិងពលវេទនានៃឧបរាជប្រទេសឥណ្ឌា** (*Vasco de Gama. Légende et tribulations du vice-roi des Indes*) ប៉ារីស បណ្ណាធិការ អាល់ម៉ា គ.ស. ២០១២ និងជាភាសាអង់គ្លេស **អាជីវកម្មនិងរឿងនិទាននៃលោក វ៉ាស្កូ ដឺ ហ្គាម៉ា** (*The Career and Legend of Vasco de Gama*) ខេមប្រ៊ិដហ្ស៍ គ្រឹះស្ថានបោះពុម្ពផ្សាយរបស់ ស.វ. ខេមប្រ៊ិដហ្ស៍ គ.ស. ១៩៩៧ ។

## កំណែពាក្យខុសក្នុង **សិក្សាចក្រ** លេខ ១២-១៣ ច្បាប់ជាភាសាបារាំងនិងអង់គ្លេស

ក.=កំណត់ចំណាំ; ប.=បន្ទាត់ទី ...

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ១៣ | ក.១, ប.៣ | Cant the Subaltern Speak? | Can the Subaltern Speak? |
| ១៣ | ក.៣, ប.៦ | Anna Laura Stoler | Ann Laura Stoler |
| ១៦ | ក.១៨, ប.១ | *Rule et Response* | *Rule and Response* |
| ២១ | ក.១, ប.២-៣ | Can't the Subaltern Speak? | Can the Subaltern Speak? |
| ២១ | ក.៣, ប.៥ | Anna Laura Stoler | Ann Laura Stoler |
| ២៤ | ក.១៨, ប.១ | *Rule et Response* | *Rule and Response* |
| ៣០ | ៣៥ | depuis 1861 | depuis 1860 |
| ៣០ | ក.១, ប.១ | « Communication et modernisation | « Colonisation et modernisation |
| ៣២ | ក.១២, ប.១ | THIOUNN, 2007 | THIOUNN, 2006 |
| ៥០ | ៨-៩ | Une entrevue à lieu | Une entrevue a lieu |
| ៥៨ | ១០-១១ | *Voyage dans l'Indochine, 1848-1856,* | *Voyage dans l'Indo-Chine, 1848-1856,* |
| ៦១ | ១៣-១៤ | quandrangulaire | quadrangulaire |
| ១៤០ | ក.៤ | Paris, EFEO-Association d'Histoire des | Caen, Bibliothèque d'Histoire rurale/ |
| | ប.៤ | sociétés rurales, Monts, 2008, 356 p. | AHSR, 2008, 354 p. |
| ១៥៦ | ១៦ | Herbert Warrington Smyth | Herbert Warington Smyth |
| ១៥៦ | ក.២៩, ប.១ | Herbert Warrington Smyth | Herbert Warington Smyth |
| ១៥៨ | ១០ | Warrington Smyth | Warington Smyth |
| ១៥៨ | ១២ | Cecile Rhodes | Cecil Rhodes |
| ១៦១ | ១ | Bo Irem (บ่ออีเรม) | Bo Irem (บ่ออีเล็ม) |
| ១៦០ | ៣៥ | Bo Na Wong (บ่อนาวงค์) | Bo Na Wong (บ่อนาวง) |
| ១៦១ | ១០ | Warrington Smyth | Warington Smyth |
| ១៦៨ | ៣១ | il était le frère aîné de l'ingénieur | il était le frère cadet de l'ingénieur |
| ១៦៩ | ២០ | de Beylié à reçut | de Beylié a reçu |
| ១៧១ | ៣២ | Il à a son actif | Il a à son actif |
| ១៧៤ | ២២ | à de détours archéologiques | à des détours archéologiques |
| ១៧៤ | ២៧ | la *Kaalad* des Beni Hammad | la *Kalâa* des Beni Hammad |
| ១៧៥ | ១ | d'une race considérée comme dégénéré | d'une race considérée comme dégénérée |
| ១៧៥ | ២២ | aidée en sous main | aidée en sous-main |
| ១៧៦ | ៣៣ | six jours de trajets | six jours de trajet |
| ១៧៧ | ១៦ | à l'aide d'affiches de couleurs édité | à l'aide d'affiches de couleur éditées |
| ១៧៧ | ៣១ | toute une carrière passé à | toute une carrière passée à |
| ១៧៧ | ៣២ | sous quelque forme qu'elle puisse avoir | sous quelque forme qu'il puisse avoir |
| ១៧៩ | ក.១, ប.១ | *Voyage en Indo-Chine* | *Voyage dans l'Indo-Chine* |
| ១៧៩ | ក.៣, ប.២ | Voir Danièle BAL | Voir Danielle BAL |
| ១៧៩ | ក.៣ | Voir Danièle BAL ... | Voir Danielle BAL ... |
| | ប.២-៣ | Grenoble, Éditions 5 continents | Milan, Musée de Grenoble – 5 Continents |
| ១៨០ | ក.៥, ប.៤ | avait à l'origine de la révolte | avait été à l'origine de la révolte |
| ១៨២ | ១៦ | et de s'affranchir de la contraint | et de s'affranchir de la contrainte |
| ១៨៦ | ក.២១, ប.១ | *Des Pionniers en Extrême-Histoire* | *Des pionniers en Extrême-Orient. Histoire* |
| ១៩៧ | ១៨ | from February 28, 1908 May 1, 1908 | from February 28, 1908 to May 1, 1908 |
| ១៩៨ | ២៣ | the narrator refuses call him directly | the narrator refuses to call him directly |

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ២០០ | ១៤ | in on their way back from Angkor | on their way back from Angkor |
| ២០១ | ១១-១២ | on grounds aesthetic, political and economic | on aesthetic, political and economic grounds |
| ២០៩ | ក. ១១, ប. ១ | *in* Oissila SAADIA | *in* Oissila SAAÏDIA |
| ២០៩ | ក. ១៣, ប. ៣ | Oissila SAADIA et Laurick ZERBINI | Oissila SAAÏDIA et Laurick ZERBINI |
| ២១២ | ១១ | Il fait parti de ces coloniaux | Il fait partie de ces coloniaux |
| ២១៤ | ក. ៤០, ប. ២ | p. 377-417, p. 3. | p. 377-417, p. 378. |
| ២១៦ | ១ | alors que l'ECA | alors que l'EAC |
| ២១៧ | ក. ៥៧, ប. ១ | HOANG VAN CO | HOÀNG VĂN CẨN |
| ២១៨ | ៣៥ | SAADIA, Oissila et Laurick ZERBINI | SAAÏDIA, Oissila et Laurick ZERBINI |
| ២១៩ | ក. ១, ប. ៥ | 418 p. | 411 p. |
| ២២៤ | ក. ៣២, ប. ៤ | Columbia University, 2001 | Columbia University, 2000 |
| ២២៦ | ១៨ | sur la carte de 1866 | sur la carte de 1886 |
| ២២៧ | ១ | *Musée khmer, 1919* | *Musée khmer, 1909* |
| ២២៧ | ២ | *Musée khmer, 1919* | *Musée khmer, 1909* |
| ២៣៨ | ក. ៦, ប. ៧-៨ | Furthermore, Phnom Bakheng, the site of this scene in *La Route du plus fort*, is today where tourists throng to watch a panoramic sunset over the Angkor Wat temple complex. | Angkorian hill-top temples continue to attract tourists seeking panoramic views, as in this novel, where the protagonists likely visited Phnom Banan. |
| ២៤២ | ប. ១៧-១៨ | ravaged by the west" (589), | ravaged by the west" (559), |
| ២៤៤ | ក. ១៤, ប. ២ | Recycling the 'Colonial Harem' Women | Recycling the 'Colonial Harem'? Women |
| ២៥០ | ប. ១ | au cœur la jungle | au cœur de la jungle |
| ២៥០ | ក. ៧, ប. ៣-៤ | *Voyage dans l'Indo-Chine, 1848-1857* | *Voyage dans l'Indo-Chine, 1848-1856* |
| ២៥៧ | ក. ៣៤ | Voir l'article de Jean-François KLEIN dans le présent numéro. | Roland MEYER, *Saramani, danseuse khmèr*, Saïgon, A. Portail, 1919 ; réédition, *Saramani, danseuse cambodgienne*, Charpentier Fasquelle, 1922, réédité par Kailash ; *Komlah, visions d'Asie*, Pierre Roger, 1930. |
| ២៥៧ | ក. ៣៥, ប. ១-៣ | Roland MEYER, *Saramani, danseuse khmèr*, Saïgon, A. Portail, 1919 ; réédition, *Saramani, danseuse cambodgienne*, Charpentier Fasquelle, 1922, réédité par Kailash ; *Komlah, visions d'Asie*, Pierre Roger, 1930 ; | MAKHALI-PHAL, *La favorite de dix ans ... Narayana ou celui qui se meut sur les eaux*, Albin Michel, 1942. |
| ២៦៥ | ក. ៥, ប. ៤ | *1958-1954* | *1858-1954* |